ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខៈ..០៥៤៤...អ.ប.ស្ថ

# សេចក្តីជូនដំណឹង

ក្រសួងបរិស្ថានមានកិត្តិយសសូមជម្រាបជូនដល់ ឯកឧត្តម លោកជំទាវ លោក-លោកស្រីដែលជាម្ចាស់គម្រោងឯកជន-សាធារណៈ ដៃគូអភិវឌ្ឍន៍ទាំងអស់ និងសាធារណជនមេត្តាជ្រាបថា ក្រសួងបរិស្ថានបានដាក់ចេញនូវតារាងបញ្ជាក់ (Check List) សម្រាប់សំណើសុំផ្សេងៗដែលពាក់ព័ន្ធនឹងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីពន្លឿនពេលវេលា ប្រសិទ្ធភាពការងារ និងតម្លាភាពរដ្ឋបាលដូចមានចែងតាមចំណុចខាងក្រោម៖

**១- សំណើសុំពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងពេញលេញ សម្រាប់គម្រោងសាធារណៈ**

| ល.រ | ឯកសារភ្ជាប់/ឯកសារយោង | ចំនួនច្បាប់ |
|---|---|---|
| ១ | ពាក្យសុំពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម | ០១ ច្បាប់ |
| ២ | កិច្ចព្រមព្រៀង/ឯកសារពាក់ព័ន្ធផ្សេងៗរបស់គម្រោង (ប្រសិនបើមាន) | ០៣ ច្បាប់ |
| ៣ | សៀវភៅសិក្សាបុរេលទ្ធភាព/សមិទ្ធិលទ្ធភាព និងផែនការមេរបស់គម្រោង | ០៣ ច្បាប់ |
| ៤ | ផែនទី ឬប្លង់ទីតាំងរបស់គម្រោង | ០៣ ច្បាប់ |
| ៥ | លិខិតផ្ទេរសិទ្ធិជូនក្រុមហ៊ុនទីប្រឹក្សា (ប្រសិនបើមាន) | ០៣ សន្លឹក |
| ៦ | របាយការណ៍ EIA ដំបូង/ពេញលេញជាភាសាខ្មែរ មានបោះត្រាពីម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា | ១៥ ក្បាល |

**២- សំណើសុំពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងពេញលេញ សម្រាប់គម្រោងឯកជន**

| ល.រ | ឯកសារភ្ជាប់/ឯកសារយោង | ចំនួនច្បាប់ |
|---|---|---|
| ១ | ពាក្យសុំពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម | ០១ ច្បាប់ |



អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

| | | |
|---|---|---|
| ២ | របាយការណ៍ EIA ដំបូង/ពេញលេញជាភាសាខ្មែរ មានបោះត្រាក្រុមហ៊ុនម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា | ១៥ ក្បាល |
| ៣ | វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | ០៣ ច្បាប់ |
| ៤ | វិញ្ញាបនបត្រចុះបញ្ជីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០៣ ច្បាប់ |
| ៥ | លក្ខន្តិកៈរបស់ក្រុមហ៊ុនម្ចាស់គម្រោង | ០៣ ច្បាប់ |
| ៦ | សៀវភៅសិក្សាបុរេលទ្ធភាព/សមិទ្ធិលទ្ធភាព និងផែនការមេរបស់គម្រោង | ០៣ ច្បាប់ |
| ៧ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ប្រធានក្រុមហ៊ុនម្ចាស់គម្រោង | ០៣ ច្បាប់ |
| ៨ | ផែនទី ឬប្លង់ទីតាំងរបស់គម្រោង | ០៣ ច្បាប់ |
| ៩ | រូបថត ៤X៦ របស់ប្រធានក្រុមហ៊ុន | ០៣ សន្លឹក |
| ១០ | វិក្កយបត្របង់ប្រាក់ថ្លៃសេវាពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន | ០១ ច្បាប់ |
| ១១ | ប័ណ្ណកម្មសិទ្ធិ ឬកិច្ចសន្យាជួលទីតាំង | ០១ ច្បាប់ |

***ចំណាំ៖** រាល់ឯកសារភ្ជាប់/ឯកសារយោងត្រូវថតចម្លងតាមច្បាប់ដើម ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានជាផ្លូវការ។

### ៣- សំណើសុំធ្វើកិច្ចសន្យាការពារបរិស្ថានលើគម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទរបស់ក្រុមហ៊ុន សហគ្រាស និងសិប្បកម្ម

| ល.រ | ឯកសារភ្ជាប់/ឯកសារយោង | ចំនួនច្បាប់ |
|---|---|---|
| ១ | ពាក្យសុំធ្វើកិច្ចសន្យាការពារបរិស្ថានលើគម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ | ០១ ច្បាប់ |
| ២ | វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | ០១ ច្បាប់ |
| ៣ | វិញ្ញាបនបត្រចុះបញ្ជីរបស់ក្រសួងរ៉ែ និងថាមពល (ប្រសិនបើមាន) | ០១ ច្បាប់ |
| ៤ | លក្ខន្តិកៈរបស់ក្រុមហ៊ុនម្ចាស់គម្រោង | ០១ ច្បាប់ |
| ៥ | អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋាន (ប្រសិនបើមាន) | ០១ ច្បាប់ |
| ៦ | ពាក្យសុំអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋាន ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន | ០១ ច្បាប់ |
| ៧ | រូបថត ៤X៦ របស់ប្រធានក្រុមហ៊ុន | ០៣ សន្លឹក |

| | | |
|---|---|---|
| ៨ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ប្រធានក្រុមហ៊ុនម្ចាស់គម្រោង | ០១ ច្បាប់ |

*ចំណាំ៖ រាល់ឯកសារភ្ជាប់/ឯកសារយោងត្រូវថតចម្លងតាមច្បាប់ដើម ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានជាផ្លូវការ។

## ៤- សំណើសុំកិច្ចសន្យាការពារបរិស្ថានលើគម្រោងវិនិយោគរោងចក្រកាត់ដេរ រោងចក្រប៉ាក់សម្លៀកបំពាក់ រោងចក្រស្បែកជើង និងរោងចក្រឧស្សាហកម្មធុនស្រាល

| ល.រ | ឯកសារភ្ជាប់/ឯកសារយោង | ចំនួនច្បាប់ |
|---|---|---|
| ១ | ពាក្យសុំកិច្ចសន្យាការពារបរិស្ថានលើគម្រោងវិនិយោគរោងចក្រកាត់ដេរ | ០១ ច្បាប់ |
| ២ | វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | ០១ ច្បាប់ |
| ៣ | លក្ខន្តិកៈរបស់ក្រុមហ៊ុនម្ចាស់គម្រោង | ០១ ច្បាប់ |
| ៤ | វិញ្ញាបនបត្រចុះបញ្ជីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០១ ច្បាប់ |
| ៥ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ប្រធានក្រុមហ៊ុនម្ចាស់គម្រោង | ០១ ច្បាប់ |
| ៦ | ផែនទី ឬប្លង់ទីតាំងរបស់គម្រោង | ០១ ច្បាប់ |
| ៧ | ផែនការមេរបស់ក្រុមហ៊ុនម្ចាស់គម្រោង (ប្រសិនបើមាន) | ០១ ច្បាប់ |
| ៨ | ប្រកាសស្តីពីការបង្កើតរោងចក្រ/សហគ្រាស (ប្រសិនបើមាន) | ០១ ច្បាប់ |
| ៩ | វិក្កយបត្របង់ប្រាក់ថ្លៃសេវាការងារលើកិច្ចសន្យាការពារបរិស្ថាន | ០១ ច្បាប់ |
| ១០ | រូបថត ៤X៦ របស់ប្រធានក្រុមហ៊ុន | ០៣ សន្លឹក |

*ចំណាំ៖ រាល់ឯកសារភ្ជាប់/ឯកសារយោងត្រូវថតចម្លងតាមច្បាប់ដើម ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានជាផ្លូវការ។

## ៥- សំណើសុំផ្លាស់ប្តូរនាមករណ៍ និងតម្កល់លក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន សហគ្រាស និងសិប្បកម្ម

| ល.រ | ឯកសារភ្ជាប់/ឯកសារយោង | ចំនួនច្បាប់ |
|---|---|---|
| ១ | ពាក្យសុំផ្លាស់ប្តូរនាមករណ៍ និងតម្កល់លក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន | ០១ ច្បាប់ |
| ២ | វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | ០១ ច្បាប់ |
| ៣ | ប្រកាសបង្កើតរោងចក្ររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ០១ ច្បាប់ |
| ៤ | វិញ្ញាបនបត្រចុះបញ្ជីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០១ ច្បាប់ |

| | | |
|---|---|---|
| ៥ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ប្រធានក្រុមហ៊ុនម្ចាស់គម្រោង | ០១ ច្បាប់ |
| ៦ | លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុនម្ចាស់គម្រោង | ០១ ច្បាប់ |
| ៧ | ផែនការមេរបស់ក្រុមហ៊ុនម្ចាស់គម្រោង (ប្រសិនបើមាន) | ០១ ច្បាប់ |
| ៨ | វិក្កយបត្របង់ប្រាក់ថ្លៃសេវាការងារ | ០១ ច្បាប់ |
| ៩ | រូបថត ៤X៦ របស់ប្រធានក្រុមហ៊ុន | ០៣ សន្លឹក |

*ចំណាំ៖ រាល់ឯកសារភ្ជាប់/ឯកសារយោងត្រូវថតចម្លងតាមច្បាប់ដើម ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានជាផ្លូវការ។

៦- សំណើសុំផ្លាស់ប្តូរ ឬពង្រីកទីតាំង ឬពង្រីកខ្សែសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន សហគ្រាស និងសិប្បកម្ម

| ល.រ | ឯកសារភ្ជាប់/ឯកសារយោង | ចំនួនច្បាប់ |
|---|---|---|
| ១ | ពាក្យសុំផ្លាស់ប្តូរ ឬពង្រីកទីតាំង ឬពង្រីកខ្សែសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន | ០១ ច្បាប់ |
| ២ | វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | ០១ ច្បាប់ |
| ៣ | ប្រកាសបង្កើតរោងចក្ររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ០១ ច្បាប់ |
| ៤ | វិញ្ញាបនបត្រចុះបញ្ជីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០១ ច្បាប់ |
| ៥ | លិខិតអនុញ្ញាតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ប្រសិនបើមាន) | ០១ ច្បាប់ |
| ៦ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ប្រធានក្រុមហ៊ុនម្ចាស់គម្រោង | ០១ ច្បាប់ |
| ៧ | លក្ខន្តិកៈរបស់ក្រុមហ៊ុនម្ចាស់គម្រោង | ០១ ច្បាប់ |
| ៨ | ផែនការមេរបស់ក្រុមហ៊ុនម្ចាស់គម្រោង (ប្រសិនបើមាន) | ០១ ច្បាប់ |
| ៩ | វិក្កយបត្របង់ប្រាក់ថ្លៃសេវាការងារ | ០១ ច្បាប់ |
| ១០ | រូបថត ៤X៦ របស់ប្រធានក្រុមហ៊ុន | ០៣ សន្លឹក |

*ចំណាំ៖ រាល់ឯកសារភ្ជាប់/ឯកសារយោងត្រូវថតចម្លងតាមច្បាប់ដើម ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានជាផ្លូវការ៕

៧- សំណើសុំចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

| ល.រ | ឯកសារភ្ជាប់/ឯកសារយោង | ចំនួនច្បាប់ |
|---|---|---|
| ១ | ពាក្យស្នើសុំការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សា | ០១ ច្បាប់ |
| ២ | ប្រកាសលេខ២១៥ ប្រក.បស្ត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍ EIA | ០១ ច្បាប់ |
| ៣ | វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | ០៣ ច្បាប់ |
| ៤ | លិខិតបញ្ជាក់ទីតាំងការិយាល័យក្រុមហ៊ុនដោយមានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន | ០៣ ច្បាប់ |
| ៥ | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ប្រធានក្រុមហ៊ុន | ០៣ ច្បាប់ |
| ៦ | លក្ខន្តិកៈរបស់ក្រុមហ៊ុន | ០៣ ច្បាប់ |
| ៧ | រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន | ០៣ ច្បាប់ |
| ៨ | សាវតាររបស់ក្រុមហ៊ុន | ០៣ ច្បាប់ |
| ៩ | ប្រវត្តិរូបរបស់ប្រធានក្រុមហ៊ុន | ០៣ ច្បាប់ |
| ១០ | ប្រវត្តិរូបរបស់ប្រធានក្រុមបច្ចេកទេស | ០៣ ច្បាប់ |
| ១១ | ប្រវត្តិរូបរបស់អ្នកជំនាញការបច្ចេកទេស | ០៣ ច្បាប់ |
| ១២ | ប្រវត្តិរូបរបស់អ្នកជំនួយការបច្ចេកទេស | ០៣ ច្បាប់ |
| ១៣ | សញ្ញាបត្ររបស់ប្រធានក្រុមហ៊ុន ប្រធានក្រុមបច្ចេកទេស អ្នកជំនាញការបច្ចេកទេស និងអ្នកជំនួយការបច្ចេកទេស | ០៣ ច្បាប់ |
| ១៤ | រូបថត ៤X៦ របស់ប្រធានក្រុមហ៊ុន ប្រធានក្រុមបច្ចេកទេស អ្នកជំនាញការបច្ចេកទេស និងអ្នកជំនួយការបច្ចេកទេស | ០៣សន្លឹក/នាក់ |

*ចំណាំ៖ រាល់ឯកសារភ្ជាប់/ឯកសារយោងត្រូវថតចម្លងតាមច្បាប់ដើម ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានជាផ្លូវការ។

៨- សំណើសុំគោលការណ៍ឯកភាពលើការចុះសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងពិនិត្យលើលក្ខខណ្ឌការងាររបស់គម្រោង

| ល.រ | ឯកសារភ្ជាប់/ឯកសារយោង | ចំនួនច្បាប់ |
|---|---|---|
| ១ | ពាក្យស្នើសុំការចុះសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ក្រុមហ៊ុន និង | ០១ ច្បាប់ |

| | | |
|---|---|---|
| | ឯកភាពលើសៀវភៅលក្ខខណ្ឌការងារ (ToR) | |
| ២ | សៀវភៅលក្ខខណ្ឌការងារ (ToR) តាមទម្រង់របស់នាយកដ្ឋាន EIA<br>ក. មានការចុះហត្ថលេខា និងកាលបរិច្ឆេទត្រឹមត្រូវ<br>ខ. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាមួយគម្រោងវិនិយោគ<br>គ. ផែនការមេ/សៀវភៅសិក្សាបុរេសមិទ្ធិលទ្ធភាពរបស់ម្ចាស់គម្រោង<br>ឃ. លិខិតផ្ទេរសិទ្ធិចុះសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានរវាងម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា<br>ង. លិខិតចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សា | ១៥ ក្បាល |
| ៣ | វិក្កយបត្របង់សេវាពិនិត្យ និងផ្តល់យោបល់លើលក្ខខណ្ឌការងារនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | ០១ ច្បាប់ |

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក-លោកស្រី ដែលជាម្ចាស់គម្រោងឯកជន-សាធារណៈ ដៃគូអភិវឌ្ឍន៍ទាំងអស់ និងសាធារណជន ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់៕

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧